# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការកែសំរួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ លើវិស័យមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មអនុក្រឹត្យលេខ ៧៦ អនក្រ / បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១.- កែសំរួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ លើវិស័យមីន ដូចខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **សម សុត្ថា** អគ្គលេខាធិការ អាជ្ញាធរមីនកម្ពុជា | សមាជិក |
| ៣-ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤-ឯកឧត្តម **សែម សុវណ្ណនី** អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា | សមាជិក |

www.pheakdeylaw.com

៥-ឯកឧត្តម **ឡេង សុជា** អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា សមាជិក

៦-ឯកឧត្តម **លឹម វ៉ាន់** អគ្គនាយក នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៧-ឯកឧត្តម **អ៊ុក គឹមលេខ** ប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ ក្រសួងមហាផ្ទៃ សមាជិក

៨-ឯកឧត្តម **ស ចាន់ធី** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី សមាជិក

៩-លោក **ចាន់ រដ្ឋា** ប្រធាននាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យអាជ្ញាធរមីន សមាជិក

១០-លោក **ព្រំ សុភមង្គល** អនុប្រធាននាយកដ្ឋានបទប្បញ្ញត្តិ និងត្រួតពិនិត្យ អាជ្ញាធរមីនកម្ពុជា លេខាធិការ

១១-លោក **គង់ វឌ្ឍនា** ប្រធានផ្នែកសេដ្ឋកិច្ច សង្គម នៃអាជ្ញាធរមីនកម្ពុជា លេខាធិការ

១២-ឯកឧត្តម **ហេង រតនា** អគ្គនាយករងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អ្នកសង្កេតការណ៍

ប្រការ ២.- ក្រុមការងារបច្ចេកទេសចំរុះមានភារកិច្ចសម្របសម្រួលរាល់ការងាររវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ លើវិស័យមីននៅកម្ពុជា ។

ប្រការ ៣.- ក្រុមការងារបច្ចេកទេសចំរុះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរមីនកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៧*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

-មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

-ដូចប្រការ ៤

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com